Open Development Cambodia
www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 224 782
contact@opendevcam.net

# ឱកាសទទួលបានការគាំទ្រលើការស្រាវជ្រាវសារណាបទបញ្ចប់ការសិក្សា សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រ

Mini-grants for Bachelor Research Support Opportunity

(Only Student from Department of Natural Resource Management,

Royal University of Phnom Penh)

អង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី) ជាស្ថាប័នដែលធ្វើការនៅលើបណ្តាញអ៊ិនធឺណែត ដោយប្រមូលផ្តុំទិន្នន័យដែលមានជាសាធារណៈ និងដោយមិនគិតថ្លៃ។ អូឌីស៊ី ផ្តល់ព័ត៌មានត្រឹមត្រូវ និងថ្មីបំផុតដល់សាធារណៈជនអំពីប្រទេសកម្ពុជា អំពីការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ប្រទេស។ ការផ្តល់ទិន្នន័យដោយទូលាយ របស់អូឌីស៊ី ធានាថា សម្ភារៈឯកសារ និងព័ត៌មាន អាចឱ្យអ្នកប្រើប្រាស់ទាំងអស់ទទួលបានសម្រាប់ ប្រើប្រាស់ និងទាញយកតាមតម្រូវការ។

ដើម្បីចូលរួមបង្កើនសមត្ថភាពដល់និស្សិត និងគាំទ្រ នៅក្នុងការសរសេរសារណាបទសម្រាប់ថ្នាក់បញ្ចប់ ព្រមទាំងស្ថិតក្រោមកិច្ចសហការរវាង **អង្គការទិន្នន័យអំពីការអភិវឌ្ឍ** និង **ដេប៉ាតឺម៉ង់ គ្រប់គ្រង និងអភិវឌ្ឍន៍ធនធានធម្មជាតិ** នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ អូឌីស៊ី នឹងធ្វើការគាំទ្រថវិកា ដល់ការសរសេរសារណាបទ របស់និស្សិត ដែលផ្តោតទៅលើ **ការគ្រប់គ្រងធនធានធម្មជាតិ (ដីធ្លី និងព្រៃឈើ)**។ អូឌីស៊ី នឹងផ្តល់ការគាំទ្រជាថវិកា សម្រាប់សារណាបទ **ចំនួនបី** ដែលមិនលើសពី **៣៥០ដុល្លាអាមេរិក** សម្រាប់សារណានីមួយៗ។

## លក្ខខណ្ឌជ្រើសរើស

- ប្រធានបទនៃសារណាបទ ត្រូវទាក់ទងនឹង **ធនធានធម្មជាតិ (ដីធ្លី និងព្រៃឈើ)**។
- ប្រធានបទអាចសរសេរជាក្រុម ឬម្នាក់ឯង។
- កំពុងសិក្សាឆ្នាំទី៤ **នៃដេប៉ាតឺម៉ង់ គ្រប់គ្រង និងអភិវឌ្ឍន៍ធនធានធម្មជាតិ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ**។ និស្សិតស្រីត្រូវបានផ្តល់អាទិភាពខ្ពស់ក្នុងការជ្រើសរើស។
- មានភាពអំណត់អត់ធន់ក្នុងការស្រាវជ្រាវ និងមានឆន្ទៈខ្ពស់ក្នុងការរៀនសូត្រដើម្បីអភិវឌ្ឍខ្លួនឯង
- មានកម្រិតភាសាអង់គ្លេសសមរម្យ (អាចនិយាយ និងសរសេរបានខ្លះៗ)។
- រយៈពេលនៃការស្រាវជ្រាវ ពី៤ ទៅ៦ខែ។



#43, Street 208, Sangkat Boeung Rain, Khan Daun Penh
Phnom Penh, Cambodia.

Open Development Cambodia
www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 224 782
contact@opendevcam.net

**ការដាក់ពាក្យស្នើសុំត្រូវភ្ជាប់មកជាមួយនូវ៖**

១. ពាក្យស្នើសុំ (Application Form) ចំនួន១ច្បាប់ (អាចទាញយកពី https://tinyurl.com/y6284j2o)

២. គម្រោងសិក្សាស្រាវជ្រាវ (Proposal) ដែលរួមមាន មូលហេតុនៃការជ្រើសរើសប្រធានបទ វិធីសាស្ត្រស្រាវជ្រាវ ពេលវេលានៃការសិក្សា និងផែនការថវិកា

៣. លិខិតអនុញ្ញាតឱ្យធ្វើការស្រាវជ្រាវទៅលើប្រធានបទចេញដោយសាកលវិទ្យាធិការសាមី

៤. ប្រវត្តិរូបសង្ខេប១ច្បាប់ ដែលមានភ្ជាប់នូវឈ្មោះអ្នកអះអាង (Referee) ចំនួន០២នាក់

៥. កាតសម្គាល់ខ្លួននិស្សិត (ថតចម្លង ១ច្បាប់)

និស្សិតត្រូវរៀបចំបំពេញពាក្យស្នើសុំ និងបញ្ជូនមកកាន់ **ដេប៉ាតឺម៉ង់ គ្រប់គ្រង និងអភិវឌ្ឍន៍ធនធានធម្មជាតិ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ**។

កាលបរិច្ឆេទទទួលពាក្យគឺចាប់ពីថ្ងៃផ្សាយដំណឹងនេះរហូតដល់**ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០១៩ ម៉ោង ១៧៖០០នាទី** ហើយការប្រកាសលទ្ធផលនឹងផ្ញើជូនតាមអ៊ីម៉ែលដែលបានដាក់ពាក្យ។ ដើម្បីទទួលបានឯកសារពាក់ព័ន្ធសម្រាប់ពាក្យស្នើសុំ និស្សិតអាចចូលតាមតំណភ្ជាប់នេះ៖ https://tinyurl.com/y6284j2o ។ សម្រាប់ព័ត៌មានបន្ថែម និស្សិតអាចទំនាក់ទំនងមក កញ្ញា ឌុច សុធាវីន (**អង្គការទិន្នន័យអំពីការអភិវឌ្ឍ**) តាមរយៈទូរស័ព្ទលេខ៖ **០៩៣ ៧១៨ ៧២៤ ឬអ៊ីម៉ែល** sotheavin@opendevcam.net។

**សូមបញ្ជាក់៖ ក្រោយពេលបញ្ចប់សារណាបទ និស្សិតត្រូវបញ្ជូនសេចក្ដីសង្ខេបនៃសារណាបទទាំងមូល (Working Paper) យ៉ាងតិច ៣ឬ៤ទំព័រ ជាភាសាអង់គ្លេស មកកាន់ អង្គការទិន្នន័យអំពីការអភិវឌ្ឍ។**



#43, Street 208, Sangkat Boeung Rain, Khan Daun Penh
Phnom Penh, Cambodia.